# របាយការណ៍សង្ខេបស្ដីពីការវាយតម្លៃបឋម

( Preliminary Assessment-PA )

## អនុក្រឹត្យស្ដីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ ឆ្នាំ២០០៧

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខយោង : ០០០០០២១

កាលបរិច្ឆេទចាប់ផ្ដើម : ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤

កាលបរិច្ឆេទបញ្ចប់ : ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤

ការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ មានគោលបំណងលើកកម្ពស់សុវត្ថិភាពផលិតផលសាច់សត្វនិងបរិស្ថានឲ្យបានជាអតិបរិមា។ អាជីវករប្រកបរបរពិឃាតសត្វសម្រាប់ផ្គត់ផ្គង់ទីផ្សារត្រូវសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចក្នុងដំណើរការរបស់ខ្លួន។ នេះជាប្រធានបទមួយដែលត្រូវបានជ្រើសរើសមកធ្វើការសិក្សានិងវាយតម្លៃបឋមដោយប្រើប្រាស់វិធីសាស្ត្រ RIA។ ក្នុងដំណើរការសិក្សានិងវិភាគលើប្រធានបទនេះ ជម្រើស២ គឺ ទី១- វាយតម្លៃលើអនុក្រឹត្យស្ដីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងទី២- ពង្រឹងការអនុវត្តអនុក្រឹត្យលេខ២៩ចាស់ត្រូវបានយកមកពិចារណាដើម្បីដោះស្រាយបញ្ហា និងសម្រេចគោលបំណងដែលចង់បាន។ ក្នុងដំណើរការ RIA ការវិភាគបន្ទុកចំណាយនិងផលចំណេញ (CBA) គឺជាធាតុដ៏សំខាន់សម្រាប់វិភាគនិងថ្លឹងថ្លែងជម្រើសទាំងពីរនេះថាតើជម្រើសមួយណាផ្ដល់ផលចំណេញច្រើនជាងដល់សង្គមនិយាយជារួម។ លទ្ធផលនៃការសិក្សាវាយតម្លៃបឋមមានដូចខាងក្រោមៈ

### ១.អំពីបន្ទុកចំណាយ

#### ជម្រើសទី១

តាមការវិភាគអំពីបន្ទុកចំណាយលើជម្រើសទី១ បង្ហាញថា ធុរកិច្ចលើវិស័យនេះទាំងអស់ចំណាយ **៦ ៣៨២ ២៩៣** ដុល្លារ ស្មើនឹង**៨៣%** នៃបន្ទុកចំណាយសរុប ដែលម្ចាស់សត្តឃាតដ្ឋាន១ត្រូវចំណាយជាមធ្យម **៥២ ៧៤៦** ដុល្លារ។ ប៉ុន្តែអាជីវករវិនិយោគក្នុងឆ្នាំដំបូងអស់ជាមធ្យម **៥០ ០០០** ដុល្លារ លើការសាងសង់សត្តឃាតដ្ឋានមួយកន្លែង ហើយអាចធ្វើអាជីវកម្មជារៀងរហូត ដោយគ្រាន់តែសុំបន្តលិខិតអនុញ្ញាតក្នុងពេល៥ឆ្នាំម្ដង។ ដូច្នេះ សត្តឃាតដ្ឋាន១ ដើម្បីអនុវត្តតាមបញ្ញត្តិកម្ម (ជម្រើសទី១) ចំណាយត្រឹមតែ **២ ៧៤៦** ដុល្លារប៉ុណ្ណោះ បើដកថ្លៃការសាងសង់ចេញ។ ម្យ៉ាងទៀត

ជាមធ្យមក្នុង១ថ្ងៃ សត្តឃាតដ្ឋាន១អាចពិឃាតគោបាន៣ក្បាល និងជ្រូក២២ក្បាល ដែលអាចរកប្រាក់ចំណេញប្រមាណ **៥ ៤៧០** ដុល្លាក្នុង១ខែ បើតាមលទ្ធផលសម្ភាសន៍ជាមួយអាជីវករ មន្ត្រីបសុព្យាបាលមានសមត្ថកិច្ច និងសមត្ថកិច្ចពាក់ព័ន្ធ។ រីឯរដ្ឋាភិបាលមានបន្ទុកចំណាយចំនួន **១ ២៩១ ៥១៨** ដុល្លារ ស្មើនឹង **១៧%** នៃចំណាយសរុប ស្មើនឹង **៧%** នៃថវិកាប្រចាំឆ្នាំរបស់ កសក ដែលជាតួលេខមួយខ្ពស់។

**ជម្រើសទី២**

អាជីវករមិនបានរងនូវបន្ទុកចំណាយលើបែបបទ លិខិតអនុញ្ញាតនានាទេ ដោយគ្រាន់តែមានបន្ទុកចំណាយរដ្ឋបាលក្នុងការចូលរួមក្នុងដំណើរការផ្សព្វផ្សាយប៉ុណ្ណោះ និងការសាងសង់សត្តឃាតដ្ឋានបន្ថែមចំនួន ៤០ ដោយផ្អែកលើតម្រូវការទីផ្សារ។ យើងឃើញថា **៣០៧** ធុរកិច្ចមានបន្ទុកចំណាយ **៩៨៣ ៥៥៣** ដុល្លារ ក្នុងនោះ ធុរកិច្ច១ជាមធ្យមមានបន្ទុកចំណាយ **៣ ២០៤** ដុល្លារ ដែលជាចំណាយបន្ថែមតាមបទដ្ឋានចាស់ រីឯប្រាក់ចំណេញមានកម្រិតខ្ពស់ ពីព្រោះ ធុរកិច្ចនីមួយៗមិនបានរងបន្ទុកចំណាយកាតព្វកិច្ចច្រើនដូចជម្រើសទី១ទេ។ ចំពោះរដ្ឋាភិបាលវិញចំណាយ **៤៩ ៧៥៩** ដុល្លារ បើប្រៀបធៀបនឹងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្មើនឹង **០,០០៣%** ប៉ុណ្ណោះ ដែលជាទំហំនៃការចំណាយមិនគួរឲ្យកត់សម្គាល់ឡើយ ។

**២.អំពីផលចំណេញ**

**ជម្រើសទី១**

ជម្រើសទី១ផ្តល់ផលចំណេញ ដូចខាងក្រោមៈ

- ការពារបរិស្ថាន និងទប់ស្កាត់បាននូវការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅមនុស្ស
- ធ្វើឲ្យសាច់សត្វមានសុវត្ថិភាព និងបង្កើនទំនុកចិត្តដល់អ្នកប្រើប្រាស់
- បង្កើនការប្រកួតប្រជែងតាមរបត់សេដ្ឋកិច្ចទីផ្សារ
- ធ្វើឲ្យមានប្រសិទ្ធភាពដល់ការគ្រប់គ្រង ស្ថិតិសត្តឃាតដ្ឋាន ចំនួនសត្វ និងបរិមាណសាច់សត្វនៅលើទីផ្សារ
- រដ្ឋាភិបាលទទួលបានចំណូលពីសត្តឃាតដ្ឋាន ដូចជា តម្លៃលិខិតអនុញ្ញាត និងសោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងសាច់សត្វ។ល។ ចំនួនប្រមាណ **៦៥៧ ៩៨៤** ដុល្លារ ដែលជាចំណូលប្រចាំឆ្នាំ (យោងតាមការគណនា)។

**ជម្រើសទី២**

ជម្រើសទី២ ផ្តល់ផលចំណេញតិចតួច ដោយសារកត្តាមួយចំនួន ដូចខាងក្រោមៈ

- ការប្រកួតប្រជែងមានកម្រិតទាប និងមិនទាន់សមស្របតាមរបត់សេដ្ឋកិច្ចទីផ្សារសេរី

- បរិស្ថាន និងការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅមនុស្សរងហានិភ័យខ្ពស់

- ការគ្រប់គ្រងសត្តឃាតដ្ឋាន ផលិតកម្មសាច់ និងស្ថិតិមិនសមស្របនឹងកម្រិតអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន

- ការបង់ចំណូលពីសត្តឃាតដ្ឋានទៅក្នុងថវិកាជាតិមិនច្បាស់លាស់ ។

## ៣.សេចក្តីសន្និដ្ឋាន

បើទោះបីជម្រើសទី១ មានបន្ទុកចំណាយច្រើនជាងជម្រើសទី២ក៏ដោយ ក៏ជម្រើសទី១ នេះគួរត្រូវបានជ្រើសយកមកអនុវត្ត ពីព្រោះ វាផ្តល់ផលចំណេញច្រើនជាងជម្រើសទី២ ដោយធានាបាននូវសុវត្ថិភាពនិងសុខភាពសាធារណៈ កាត់បន្ថយការបំផ្លាញបរិស្ថាន បង្កើនចំណូលចូលថវិការដ្ឋ បង្កើតបរិយាកាសប្រកួតប្រជែង លើកកម្ពស់សមត្ថភាពប្រកួតប្រជែង ជាពិសេស បង្កើនប្រសិទ្ធភាពនៃគ្រប់គ្រងលើវិស័យនេះឲ្យកាន់តែប្រសើរ។

# របាយការណ៍ស្តីពីការវាយតម្លៃបឋម

## អនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ ឆ្នាំ២០០៧

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខយោង : ០០០០០២១

កាលបរិច្ឆេទចាប់ផ្តើម : ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤

កាលបរិច្ឆេទបញ្ចប់ : ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤

ទំនាក់ទំនង :

| | ឈ្មោះ | លេខទូរស័ព្ទ | អ៊ីមែល |
|---|---|---|---|
| IA-ទទួលបន្ទុក | លោក អ៊ុំ សាវី | ០១២ ៧២៧ ៦៦៤ | oum.savy@yahoo.com |
| IA-ជំនួស | លោក ហាវ ផា | ០១២ ៨៣៧ ៦៦៥ | hao_72pha@yahoo.com |
| IA-សមាជិក | លោក ខេង យ៉ាសិទ្ធ | ០១២ ៨៦៥៦១៧ | khengyasith@yahoo.com |
| IA-សមាជិក | លោក អ៊ិត ភុំ | ០១២ ៨៨៩ ៩៨១ | phum_kh@hotmail.com |
| ORIA-ទទួលបន្ទុក | លោក ឈិត រតនៈ | ០៨១ ៩៤៤ ៩១២ | Ch_rotanak77@yayoo.com |
| ORIA-ជំនួស | ល.ជ ស៊ាង សុផល្លា | ០១២ ៦៦៥២០១ | seangsophalla@yahoo.com |

### អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

អនុក្រឹត្យនេះចែងពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វ ការពារសុខភាពសត្វ ធានាគុណភាពផលិតផល និងការពារសុខភាពសាធារណៈ។ អាជីវករដែលប្រកបអាជីវកម្មពាក់ព័ន្ធនឹងការពិឃាតសត្វមានកាតព្វកិច្ច ដូចខាងក្រោម៖

- ស្នើសុំលិខិតអនុញ្ញាតបង្កើតសត្តឃាតដ្ឋាន និងអាជីវកម្មពិឃាតសត្វពីនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល (ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ)
- ស្នើសុំលិខិតអនុញ្ញាតដឹកជញ្ជូនសត្វរស់ អមដោយវិញ្ញាបនបត្រសុខភាពសត្វ
- មុនពិឃាតសត្វត្រូវឆ្លងកាត់ការត្រួតពិនិត្យដោយភ្នាក់ងារបសុពេទ្យ
- ការធ្វើអាជីវកម្មសាច់សត្វត្រូវមានបោះត្រាដោយភ្នាក់ងារបសុពេទ្យ

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះអ្នកបង្កើតសត្តឃាតដ្ឋាន អ្នកធ្វើអាជីវកម្មពិឃាតសត្វ និងអ្នកប្រកបអាជីវកម្មប្រមូលទិញសត្វ។

ប្រភេទបញ្ញត្តិកម្ម

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☑ | ☐ | ☐ | ☐ | ☐ |

សំណើនេះ មានចរិកជាបញ្ញត្តិកម្ម ហើយវាមានផលប៉ះពាល់ដល់ធុរកិច្ច

## ១. ការកំណត់បញ្ហា

| បញ្ហាសំខាន់ៗ | បញ្ញត្តិកម្មនេះមានបំណងដោះស្រាយ (*គូស✓មែន ឬមិនមែន*) | ភស្តុតាង/ភាពជាក់ស្តែង (សូមភ្ជាប់កំណត់សម្គាល់ប្រសិនបើចាំបាច់) |
|---|---|---|
| សុខភាព និងសុវត្ថិភាពសាធារណៈ | មែន | ការបរិភោគសាច់សត្វផ្ទុកដោយមេរោគធ្វើឲ្យប៉ះពាល់ដល់សុខភាពមនុស្ស។ កន្លងមក តាមរបាយការណ៍បូកសរុបការងារកសិកម្ម និងរបាយការណ៍របស់អង្គការសុខភាពពិភពលោក (WHO) បានបង្ហាញឲ្យឃើញថា ប្រភេទជំងឺផ្តាសាយបក្សីជាជំងឺកាចសាហាវឆ្លងពីសត្វទៅមនុស្សតាមរយៈការប៉ះពាល់បក្សីដោយផ្ទាល់ និងការបរិភោគសាច់បក្សីផ្ទុកជំងឺផ្តាសាយបក្សី កំពុងរីករាលនៅលើពិភពលោក។ យោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោកឆ្នាំ២០១៣ ជំងឺនេះ បណ្តាលឲ្យមនុស្សស្លាប់បាត់បង់ជីវិតអស់ចំនួន **៣៧៥** នាក់ ក្នុងនោះប្រទេសកម្ពុជាមានប្រជាពលរដ្ឋបានស្លាប់ដោយជំងឺកាចសាហាវនេះ ចំនួន **២៩** នាក់។ ក្រៅពីជំងឺផ្តាសាយបក្សី ក៏មានសាច់សត្វគោ ក្របីមានជំងឺ បានធ្វើឲ្យអ្នកបរិភោគមានជំងឺ ដូចជាជំងឺប៉េះគោក្របី ជំងឺរលាកស្រោមសួតគោក្របី ជំងឺប៉េះជ្រូក ជំងឺឈាមខ្មៅ ជំងឺឆ្កួត ជំងឺបូសខ្យល់ ជំងឺសាទឹក ជំងឺចុងអង្ករជាដើម។ ជំងឺទាំងនេះ មានលក្ខណៈកាចសាហាវ និងឆ្លងរាតត្បាតឆាប់រហ័សបំផុតគ្មានព្រំដែនកំណត់ជាក់លាក់ និងធ្វើឲ្យមានផលវិបាកខ្លាំងដល់សុខភាពសាធារណៈនិងសេដ្ឋកិច្ចសង្គម ជាពិសេស ចំពោះការធ្វើ |

| | | |
|---|---|---|
| ការការពារ និងអភិរក្ស បរិស្ថាន | មែន | ពាណិជ្ជកម្មសត្វជាអន្តរជាតិ និងផលិតផលមានដើមកំណើតពីសត្វ។ បច្ចុប្បន្ននេះ ការសម្លាប់សត្វហាលវាលដោយគ្មានការអនុញ្ញាត គ្មានបទដ្ឋានបច្ចេកទេស គ្មានការត្រួតពិនិត្យពីសមត្ថកិច្ចផលិតកម្ម និងបសុព្យាបាល បណ្តាលឲ្យប៉ះពាល់បរិស្ថាន ដូចជា កាកសំណល់ ក្លិនស្អុយ ការបង្ហូរទឹកក្រខ្វក់ សម្លេងសត្វស្រែក ការចម្លងមេរោគតាមខ្យល់។ល។ តាមការចុះសាកសួរប្រជាជនដែលរស់នៅជុំវិញសត្តឃាតដ្ឋានស្ទឹងមានជ័យនិយាយថា ចាប់ពីម៉ោង១យប់ដល់ទៀបភ្លឺ លឺសំឡេងជ្រូកស្រែក ធុំក្លិនឈ្អៀមផ្សែងភ្លើងដុតកំទេចក្រណាត់ និងសំបកកង់ជាំទឹកកោសជ្រូកហុយចូលផ្ទះ ធុំក្លិនស្អុយ។ លើសពីនេះ កាកសំណល់បង្ហូរចូលបឹងនៅខាងក្រោយផ្ទះពួកគាត់តែម្តង។ |
| សមធម៌យេនឌ័រ និង សង្គម និងការអភិរក្សវប្បធម៌ | មិនមែន | |
| ការប្រកួតប្រជែង | មែន | ការធ្វើអាជីវកម្មសាច់សត្វមានរបាំងពាណិជ្ជកម្ម នៃការចូលក្នុងទីផ្សារ ព្រោះតាមអនុក្រឹត្យលេខ ២៩ ចាស់ ក្នុងមួយស្រុក ក្រុង អនុញ្ញាតឲ្យមានសត្តឃាតដ្ឋានតែមួយកន្លែងប៉ុណ្ណោះ។ ការណ៍នេះ ធ្វើឲ្យអ្នកទទួលបានសិទ្ធិធ្វើអាជីវកម្មមានអំណាចផ្តាច់មុខក្នុងទីផ្សារ ដែលក្នុងកម្រិតណាមួយបានប៉ះពាល់ដល់ដំណើរការប្រកួតប្រជែង។ |
| ការប្រមូលព័ត៌មាន | មែន | ក្រសួងជួបការលំបាកក្នុងការទទួលបានព័ត៌មានពាក់ព័ន្ធនឹងស្ថិតិសត្តឃាតដ្ឋាន និងស្ថិតិសត្វបានសម្លាប់ ។ |
| អនុលោមតាមកិច្ចព្រមព្រៀង WTO និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត | មែន | Terrestrial Animal Health Code 2011 (OiE) |

ប្រសិនបើមានបញ្ហាផ្សេងទៀត សូម អធិប្បាយ និងផ្តល់ភស្តុតាង

| |
|---|
| វិស័យសត្តឃាតនៅព្រះរាជាណាចក្រកម្ពុជា មានភាពមិនទាន់សម័យ ខ្វះបទដ្ឋានបច្ចេកទេស និងស្តង់ដា មិនឆ្លើយតបនឹងតម្រូវការទីផ្សារ ដែលធ្វើឲ្យវិស័យនេះខ្វះភាពប្រកួតប្រជែង។ សុក្រឹត្យកម្មវិស័យនេះ ជាការចាំបាច់។ |

សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដែលពាក់ព័ន្ធ ឬប្រហាក់ប្រហែល។

| |
|---|
| ១. អនុក្រឹត្យលេខ ២៩ អនក្រ ចុះថ្ងៃទី២២ ខែវិច្ឆការ ឆ្នាំ១៩៩០ ស្តីពីសត្តឃាតដ្ឋាននិងកន្លែងពិឃាតសត្វ<br>២. សារាចរណែនាំលេខ៤១៩ កសក.សរណន ចុះថ្ងៃទី១៤/១២/១៩៩០<br>៣. សេចក្តីណែនាំលេខ ៥១៣ សនណ.កសក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីបែបបទបង្កើតគ្រប់គ្រងសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ និងការធ្វើអាជីវកម្មពិឃាតសត្វ<br>៤. ប្រកាសលេខ០ ៨៦ ប្រក.កសក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីអាករអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ។ |

ចូរបញ្ជាក់ តើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះ មិនទាន់គ្រប់គ្រាន់?

| |
|---|
| យោងតាមលិខិតបទដ្ឋានគត្តិយុត្តមានស្រាប់ គេបានសង្កេតឃើញថា មានលក្ខណៈចង្អៀត ខ្វះការប្រកួតប្រជែង និងមិនទាន់សមស្របតាមរបត់សេដ្ឋកិច្ចទីផ្សារសេរី។ ម៉្យាងវិញទៀត សមត្ថកិច្ចគ្រប់គ្រងនៅមិនទាន់សមស្របនឹងស្ថានភាពបច្ចុប្បន្ន ជាពិសេស ការបង់ចំណូលពីវិស័យឯកជនចូលក្នុងថវិកាជាតិមិនច្បាស់លាស់ ។ |

## ២. គោលបំណង

| |
|---|
| *លើកកម្ពស់សុវត្ថិភាពផលិតផលសាច់សត្វ និងបរិស្ថានឲ្យបានជាអតិបរិមា ។* |

## ៣. ជម្រើស

| |
|---|
| ១. សំណើបញ្ញត្តិកម្មៈ អនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ផលិតផសត្វ។<br><br>២. ពង្រឹងការអនុវត្តលិខិតបទដ្ឋានមានស្រាប់ ដោយលើកកម្ពស់ការយល់ដឹងអំពីការធ្វើអាជីវកម្មពិឃាតសត្វ។ |

## ៤. ការប៉ាន់ស្មានបឋមលើចំណាយការពុកិច្ច និងផលប៉ះពាល់ដល់ការប្រកួតប្រជែង

### ៤.១. ការកំណត់ភារកិច្ច និងប្រភេទចំណាយ (tasks and cost-categories)

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| **ជម្រើសទី១:** អនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ ផលិតផលសត្វ | ១. ការរៀបចំសេចក្តីព្រាង<br>២. ពិគ្រោះយោបល់<br>៣. បណ្តុះបណ្តាលសមត្ថភាពមន្ត្រី<br>៤. ការចេញលិខិតអនុញ្ញាត<br>៥. មធ្យោបាយ និងសម្ភារត្រួតពិនិត្យសាច់ និងផលិតផលសត្វ<br>៦. ការងារគ្រប់គ្រងទិន្នន័យ<br>៧. ការងារផ្សព្វផ្សាយ និងផលិតឯកសារ (ពាក្យសុំបង្កើតសត្តឃាតដ្ឋាន ពាក្យសុំធ្វើអាជីវកម្មពិឃាតសត្វ...)<br>៨. ការងារតាមដាន ត្រួតពិនិត្យ។ | ១. ការចូលរួមពិគ្រោះយោបល់<br>២. លិខិតអនុញ្ញាតបង្កើតសត្តឃាតដ្ឋាន<br>៣. លិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ<br>៤. ការសាងសង់សត្តឃាតដ្ឋាននិងឧបករណ៍បំពាក់ក្នុងសត្តឃាតដ្ឋាន<br>៥. សេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ<br>៦. លិខិតដឹកជញ្ជូនសត្វ<br>៧. វិញ្ញាបនបត្រអនាម័យសត្វ<br>៨. ចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ<br>៩. បង់សេវាត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលមានដើមកំណើតពីសត្វ<br>១០. ចូលរួមក្នុងដំណើរការត្រួតពិនិត្យរបស់សមត្ថកិច្ច ។ |
| **ជម្រើសទី២:** ពង្រឹងការអនុវត្តលិខិតបទដ្ឋានមានស្រាប់ ដោយលើកកម្ពស់ការយល់ដឹងអំពីការធ្វើអាជីវកម្មពិឃាតសត្វ។ | ១. ប្រជុំផ្សព្វផ្សាយដល់អាជីវករ<br>២. ផ្សព្វផ្សាយតាមវិទ្យុ<br>៣. ចុះត្រួតពិនិត្យតាមសត្តឃាតដ្ឋាន<br>៤. ផលិតឯកសារបោះពុម្ពឯកសារ និងរូបភាពផ្សព្វផ្សាយ។ | ១. ចូលរួមក្នុងដំណើរការផ្សព្វផ្សាយ<br>២. បង្កើតសត្តឃាតដ្ឋានថ្មីចំនួន៤០<br>៣. ការធ្វើបដិសណ្ឋារកិច្ចចំពោះការអនុវត្តច្បាប់ដោយមន្ត្រីបសុព្យាបាលមានសមត្ថកិច្ច។ |

### ៩.២. វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យ ឬប្រភេទធុរកិច្ច | ចំនួនធុរ កិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| អនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ | **អាជីវកម្មពិឃាតសត្វ** | ១២២ | របាយការណ៍ប្រចាំឆ្នាំ ២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ជម្រើសទី២: ពង្រឹងការអនុវត្តលិខិតបទដ្ឋាន ដែលមានស្រាប់ ដោយលើកកម្ពស់ការយល់ដឹងអំពីការធ្វើអាជីវកម្មពិឃាតសត្វ។ | **អាជីវកម្មពិឃាតសត្វ** | ៣០៧ | របាយការណ៍ប្រចាំឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

### ៩.៣. ប៉ាន់ស្មានចំណាយបន្ថែមរបស់ធុរកិច្ច និងរាជរដ្ឋាភិបាល

| ធុរកិច្ច | | |
|---|---|---|
| ជម្រើស | កំណើនចំណាយអនុលោមតាមបញ្ញត្តិកម្ម | ផ្តល់អំណះអំណាង |
| **ជម្រើសទី១:** អនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ។ | មិនគួរឲ្យកត់សម្គាល់ | តាមការវិភាគអំពីបន្ទុកចំណាយលើជម្រើសទី១នេះ ឃើញថា ធុរកិច្ចបានចំណាយអស់ចំនួន **៦ ៣៨២ ២៩៣** ដុល្លារ ស្មើនឹង **៨៣%** នៃបន្ទុកចំណាយសរុប ដែលម្ចាស់សត្តដ្ឋាន ១ ត្រូវចំណាយជាមធ្យម **៥២ ៧៤៦** ដុល្លារ។ ប៉ុន្តែ អាជីវករវិនិយោគក្នុងឆ្នាំដំបូងអស់ជាមធ្យម **៥០ ០០០** ដុល្លារ លើការសាងសង់សត្តឃាតដ្ឋានមួយកន្លែង ហើយអាចធ្វើអាជីវកម្មជារៀងរហូត ដោយគ្រាន់តែសុំបន្តលិខិតអនុញ្ញាតក្នុងពេល៥ឆ្នាំម្តង។ ដូច្នេះ សត្តឃាតដ្ឋាន១ ដើម្បីអនុវត្តតាមបញ្ញត្តកម្ម ចំណាយត្រឹមតែ **២ ៧៤៦** ដុល្លារប៉ុណ្ណោះ បើដកថ្លៃការសាងសង់ចេញ។ ម្យ៉ាងទៀត ជាមធ្យមក្នុង១ថ្ងៃ សត្តឃាតដ្ឋាន១អាចពិឃាត |

| | | |
|---|---|---|
| | | គោបាន៣ក្បាល និងជ្រូក២២ក្បាល ដែលអាចរកប្រាក់ចំណេញប្រមាណ ៥ ៤៧០ ដុល្លាក្នុង១ខែ បើតាមលទ្ធផលសម្ភាសន៍ជាមួយអាជីវករ មន្ត្រីបសុព្យាបាលមានសមត្ថកិច្ច និងសមត្ថកិច្ចពាក់ព័ន្ធ។ |
| **ជម្រើសទី២:** ពង្រឹងការអនុវត្តលិខិតបទដ្ឋានមានស្រាប់ ដោយលើកកម្ពស់ការយល់ដឹងអំពីការធ្វើអាជីវកម្មពិឃាតសត្វ។ | មិនគួរឲ្យកត់សម្គាល់ | អាជីវករមិនបានរងនូវបន្ទុកចំណាយលើបែបបទ លិខិតអនុញ្ញាតនានាទេ ដោយគ្រាន់តែមានចំណាយរដ្ឋបាលក្នុងការចូលរួមក្នុងដំណើរការផ្សព្វផ្សាយប៉ុណ្ណោះ និងការសាងសង់សត្តឃាតដ្ឋានបន្ថែមចំនួន ៤០ ដោយផ្អែកលើតម្រូវការទីផ្សារ។ យើងឃើញថា ៣០៧ ធុរកិច្ចមានបន្ទុកចំណាយ **៩៨៣ ៥៥៣** ដុល្លា ក្នុងនោះធុរកិច្ច១ជាមធ្យមមានបន្ទុកចំណាយ **៣ ២០៤** ដុល្លារ ដែលជាចំណាយបន្ថែម (incremental cost) លើបទដ្ឋានចាស់ រីឯប្រាក់ចំណេញមានកម្រិតខ្ពស់ ព្រោះ ធុរកិច្ចនីមួយៗមិនបានរងបន្ទុកចំណាយកាតព្វកិច្ចច្រើនដូចជម្រើសទី១ទេ។ |

| **រាជរដ្ឋាភិបាល** | | |
|---|---|---|
| **ជម្រើស** | **កំណើនចំណាយអនុលោមតាមបញ្ញត្តិកម្ម** | **ផ្តល់អំណះអំណាង** |
| **ជម្រើសទី១:** អនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ។ | គួរឲ្យកត់សម្គាល់ | រដ្ឋាភិបាលចំណាយចំនួន ១ ២៩១ ៥១៨ ដុល្លារ ស្មើនឹង ១៧% នៃចំណាយសរុប ស្មើនឹង ៧% នៃថវិកាប្រចាំឆ្នាំរបស់ កសក ដែលជាតួលេខមួយខ្ពស់។ |

| | | |
|---|---|---|
| **ជម្រើសទី២:** ពង្រឹងការអនុវត្តលិខិតបទដ្ឋានមានស្រាប់ ដោយលើកកម្ពស់ការយល់ដឹងអំពីការធ្វើអាជីវកម្មពិឃាតសត្វ។ | មិនគួរឲ្យកត់សម្គាល់ | រដ្ឋាភិបាលចំណាយ **៤៩ ៧៥៩** ដុល្លារ បើប្រៀបធៀបនឹងថវិកាប្រចាំឆ្នាំរបស់ក្រសួងស្មើនឹង ០,០០៣% ប៉ុណ្ណោះ។ |

៤.៤. ប៉ាន់ស្មានកម្រិតនៃផលចំណេញ

| ជម្រើស | ផលចំណេញ | ផ្តល់អំណះអំណាង |
|---|---|---|
| **ជម្រើសទី១:** អនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ។ | គួរឲ្យកត់សម្គាល់ | - ការពារបរិស្ថាន និងទប់ស្កាត់បាននូវការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅមនុស្ស<br>- ធ្វើឲ្យសាច់សត្វមានសុវត្ថិភាព និងបង្កើនទំនុកចិត្តដល់អ្នកប្រើប្រាស់<br>- បង្កើនការប្រកួតប្រជែង តាមរបត់សេដ្ឋកិច្ចទីផ្សារ<br>- ធ្វើឲ្យមានប្រសិទ្ធភាពដល់ការគ្រប់គ្រងស្ថិតិសត្តឃាតដ្ឋាន ចំនួនសត្វ និងបរិមាណសាច់សត្វនៅលើទីផ្សារ<br>- រដ្ឋាភិបាលទទួលបានចំណូលពីសត្តឃាតដ្ឋាន ដូចជា តម្លៃលិខិតអនុញ្ញាត និងសោហ៊ុយសេវាកម្មត្រួតពិនិត្យ អនាម័យសត្វ និងសាច់សត្វ។ល។ ចំនួនប្រមាណ **៦៥៧ ៩៨៤** ដុល្លារ ដែលជាចំណូលប្រចាំឆ្នាំ(យោងតាមការគណនា)។ |
| **ជម្រើសទី២:** ពង្រឹងការអនុវត្តលិខិតបទដ្ឋានមានស្រាប់ ដោយលើកកម្ពស់ការយល់ដឹងអំពីការធ្វើអាជីវកម្មពិឃាតសត្វ ។ | មិនគួរឲ្យកត់សម្គាល់ | ជម្រើសទីពីរនេះ ផ្តល់ផលចំណេញតិចតួច ដោយសារ កត្តាមួយចំនួនដូចខាងក្រោម៖<br>- ការប្រកួតប្រជែងមានកម្រិតទាបនិងមិនទាន់សមស្របតាមរបត់សេដ្ឋកិច្ចទីផ្សារសេរី<br>- បរិស្ថាន និងការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅមនុស្ស រងនូវហានិភ័យខ្ពស់<br>- ការគ្រប់គ្រងសត្តឃាតដ្ឋាន ផលិតកម្មសាច់ និងស្ថិតិ មិនសមស្របនឹងកម្រិត |

| | | |
|---|---|---|
| | | អភិវឌ្ឍសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន<br>- ការបង់ចំណូលពីសត្តឃាតដ្ឋាន ទៅក្នុងថវិកាជាតិមិនច្បាស់លាស់ ។ |

**៤.៥. តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ? មិនមែន**
***( ប្រសិនបើផលប៉ះពាល់ដល់ការប្រកួតប្រជែងគួរឲ្យកត់សម្គាល់ តម្រូវឲ្យធ្វើRIS)។***

| |
|---|
| បន្ទុកចំណាយរបស់ធុរកិច្ច មិនគួរឲ្យកត់សម្គាល់ បើប្រៀបធៀបនឹងចំណូលដែលធុរកិច្ចទទួលបាន។ |

**៤.៦. តើសំណើបញ្ញត្តិកម្មនេះមានផលប៉ះពាល់អវិជ្ជមានលើសមធម៌យេនឌ័រដែរឬទេ? មិនមាន**

## ៥. កិច្ចពិគ្រោះយោបល់

កិច្ចពិគ្រោះយោបល់បានធ្វើឡើងជាមួយភាគីពាក់ព័ន្ធ ដូចខាងក្រោម ៖

| ក្រុមអ្នកពាក់ព័ន្ធ | | វិធីសាស្ត្រ | សង្ខេបទស្សនៈ |
|---|---|---|---|
| ធុរកិច្ច | សមាគមធុរកិច្ច (តំណាងឲ្យ ១០% នៃវិស័យធុរកិច្ច) | មតិយោបល់ជាលាយលក្ខណ៍អក្សរ  កិច្ចប្រជុំ / ទូរស័ព្ទ | |
| អាជីវករពិឃាតសត្វ ចំនួន ០៥នាក់ នៅសត្តឃាតដ្ឋានខុសៗគ្នា | សត្តឃាតដ្ឋាន ដូចជា៖<br>១. ដំណាក់ធំ<br>២. ស្ទឹងមានជ័យ<br>៣. សែនសុខ<br>៤. និងដទៃទៀត។ | សម្ភាសន៍ផ្ទាល់ និងតាមទូរស័ព្ទ | - ចំណាយទុនច្រើនលើការសាងសង់<br>- សត្វថ្លៃ ការធ្វើអាជីវកម្មពិឃាតចំណេញតិច ឯចំណាយផ្សេងៗក្រៅផ្លូវការមានច្រើន<br>- គាំទ្រឲ្យមានសត្តឃាតដ្ឋានស្តង់ដា។ |
| អ្នកប្រើប្រាស់<br>ប្រជាពលរដ្ឋរស់នៅជិតសត្តឃាតដ្ឋានស្ទឹងមានជ័យ | ក្រុមអ្នកប្រើប្រាស់ | | |
| | អ្នកប្រើប្រាស់ចម្បងៗ (អ្នកប្រើប្រាស់ទំនិញ/សេវាកម្មអ្វីមួយក្នុងបរិមាណច្រើន) | សម្ភាសន៍ផ្ទាល់ | ប៉ះពាល់បរិស្ថានរស់នៅ |

| | | | |
|---|---|---|---|
| | អ្នកប្រើប្រាស់តូចៗ ( អ្នកប្រើប្រាស់ទំនិញ/សេវាកម្មអ្វីមួយក្នុងបរិមាណតិចតួច)។ | | |
| រាជរដ្ឋាភិបាល | ក្រសួង/ស្ថាប័ន | | |
| ១. អនុប្រធាននាយកដ្ឋាន<br>២. ប្រធាន/អនុប្រធានមន្ទីរ | នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល<br>- មន្ទីរកសិកម្មខេត្តព្រៃវែង<br>- មន្ទីរកសិកម្មរាជធានីភ្នំពេញ | កិច្ចប្រជុំ | មានការគ្រប់គ្រងបានល្អតាមសេដ្ឋកិច្ចទីផ្សារ |
| អ្នកជំនាញ<br>១. លោក ជេត ផល្លា<br>២. លោក សួង វ៉ាន់ថេន<br>៣. លោក យាន ម៉ារិទ្ធ<br>៤. លោក ឡុង គៀនផេង | មន្ទីរកសិកម្មរាជធានីភ្នំពេញ<br>អនុប្រធានការិ.បសុព្យាបាល<br>អនុប្រធានការិ.បសុព្យាបាល<br>អនុប្រធានការិ.បសុព្យាបាល<br>ប្រធានផ្នែកបសុព្យាបាល | តាមរយៈកិច្ចប្រជុំ | - មានការគ្រប់គ្រងបានល្អតាមសេដ្ឋកិច្ចទីផ្សារ<br>- មានការលំបាកក្នុងប្រមូលចំណូលនៅតាមសត្តឃាតដ្ឋាន។ |
| ផ្សេងៗ | ឈ្មោះ | | |

## ៦. សន្និដ្ឋាន

### ៦.១. សេចក្តីសង្ខេបនៃចំណាយកាតព្វកិច្ចបន្ថែមនិងផលចំណេញ

| ជម្រើស | ចំណាយរបស់ធុរកិច្ច | ចំណាយរបស់រាជរដ្ឋាភិបាល | ផលចំណេញ |
|---|---|---|---|
| ជម្រើសទី១ | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ |
| ជម្រើសទី២ | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ |

### ៦.២. តើចាំបាច់ធ្វើ RIS ដែរឬទេ?

**មិនចាំបាច់** ព្រោះថា តាមការសិក្សាបឋម បន្ទុកចំណាយរបស់ជម្រើសនេះ ចំពោះធុរកិច្ចមានកម្រិតទាប (បន្ទាប់ពីការដកចេញនូវចំណាយវិនិយោគលើការសាងសង់) ប៉ុន្តែផលចំណេញទទួលបានច្រើន។ គួរកត់សម្គាល់ថា បន្ទុកចំណាយរបស់រដ្ឋាភិបាលមានកម្រិតខ្ពស់មែន (តាមការគណនា) ប៉ុន្តែ រដ្ឋទទួលបានការប៉ះប៉ូវវិញ តាមរយៈការចេញលិខិតអនុញ្ញាត និងសោហ៊ុយសេវាកម្មត្រួត

| |
|---|
| ពិនិត្យអនាម័យសត្វនិងសាច់សត្វ។ល។ ដែលមានចំនួនប្រមាណ**៦៥៧ ៩៨៩**ដុល្លារក្នុងមួយឆ្នាំៗ។ |

### ៦.៣. ជម្រើសដែលបានជ្រើសរើស

| |
|---|
| ជាអនុសាសន៍គួរជ្រើសរើសជម្រើសទី១ គឺអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យ សត្វ សាច់ និងផលិតផលសត្វ ពីព្រោះវាផ្តល់ផលចំណេញច្រើនជាងជម្រើសទី២។ ជម្រើសទី១នេះនឹងធានាថា សត្វដែលមានជំងឺនឹងមិនអនុញ្ញាតឲ្យពិឃាតយកសាច់ទៅបរិភោគ ឬកែច្នៃធ្វើផ្សេងទេ និងធ្វើឲ្យមានមានទំនើបកម្មសត្តឃាតដ្ឋានប្រកបដោយអនាម័យនិងមានការគ្រប់គ្រងបរិស្ថានបានល្អ។ សាច់សត្វដែលមានការត្រួតពិនិត្យត្រឹមត្រូវផ្តល់ការធានាសុវត្ថិភាពខ្ពស់ចំពោះអ្នកទិញបរិភោគ និងមានតម្លៃទីផ្សារបើកចំហរ (open market price)។ ជាមួយជម្រើសនេះ ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទមានភាពងាយស្រួលក្នុងការប្រមូលទិន្នន័យ សម្រាប់បម្រើក្នុងគោលបំណងផ្សេងៗ។ |

| លក្ខណៈវិនិច្ឆ័យ | | មូលហេតុ |
|---|---|---|
| តើវាជាជម្រើសដែលមានចំណាយកាតព្វកិច្ចបន្ថែមអប្បបរមាសម្រាប់វិស័យធុរកិច្ច និងសហគមន៍ដែរឬទេ? | មិនមែន | ដោយសារបន្ទុករដ្ឋបាល និងការចំណាយវិនិយោគខ្ពស់ជាងជម្រើសទីពីរ |
| តើជម្រើសនេះផ្តល់នូវផលចំណេញអតិបរមាដែរឬទេ? | មែន | រដ្ឋាភិបាល ធុរកិច្ច និងអ្នកប្រើប្រាស់ទទួលបានផលចំណេញទាំងអស់គ្នា លើសពីនេះទៀត ជម្រើសនេះ អាចជួយការពារបរិស្ថាន និងធានាសុវត្ថិភាពសាច់ បានកម្រិតខ្ពស់។ |

ទោះបីជាលក្ខណៈវិនិច្ឆ័យមួយខាងលើអវិជ្ជមាន តែការរួមបញ្ចូលគ្នានៃលក្ខណៈវិនិច្ឆ័យទាំងពីរមានលក្ខណៈសមស្រប ចូរផ្តល់អំណះអំណាងនិងបន្តទៅចំណុចទី៧។

| |
|---|
| ទោះបីបន្ទុកចំណាយនៃជម្រើសដែលបានជ្រើសរើសខ្ពស់ជាងជម្រើសទី២មែន ប៉ុន្តែផលចំណេញនៃជម្រើសនេះរំពឹងថានឹងមានកម្រិតខ្ពស់ជាងជម្រើសទី២។ ម្យ៉ាងទៀត ជម្រើសនេះមានប្រសិទ្ធភាពក្នុងការអនុវត្ត ។ |

## ៧. ការអនុវត្ត និងការតាមដាន

ប្រសិនបើជម្រើសបញ្ញត្តិកម្មត្រូវបានជ្រើសរើស៖

៧.១. តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

| |
|---|
| នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលត្រូវរៀបចំកម្មវិធីផ្សព្វផ្សាយអនុក្រឹត្យនេះដល់អ្នកពាក់ព័ន្ធទាំងឡាយ។ មន្ត្រីនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល និងមន្ត្រីការិយាល័យផលិតកម្មនិងបសុព្យាបាលនៃមន្ទីកសិកម្មខេត្ត ក្រុង ដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធត្រូវចុះត្រួតពិនិត្យសកម្មភាពពិឃាតនិងពាណិជ្ជកម្មសាច់សត្វដល់ទីកន្លែង តាមកម្មវិធីការងារមួយដែលត្រូវបង្កើតឡើង និងត្រូវបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញ។ |

៧.២. តើគួរធ្វើការពិនិត្យ/តាមដានបញ្ញត្តិកម្មនេះឡើងវិញក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះគួរត្រូវបានពិនិត្យឡើងវិញ/តាមដានយ៉ាងដូចម្តេច និងនៅពេលណា?

| |
|---|
| យន្តការតាមដានមួយគួរត្រូវបានបង្កើតឡើង ដើម្បីពិនិត្យលទ្ធផលនៃការអនុវត្តក្នុងមួយឆ្នាំម្តង កត់ត្រាទុកនូវចំណុចខ្វះខាត នឹងស្នើកែលម្អចំណុចខ្វះខាតនេះ យ៉ាងយូររយៈពេល ៥ ឆ្នាំខាងមុខ ។ |

## អត្ថាធិប្បាយផ្សេងទៀត

| |
|---|
| បញ្ញត្តិកម្មនេះ មានសារសំខាន់និងចាំបាច់បំផុត ក្នុងបរិបទសេដ្ឋកិច្ចសម័យបច្ចុប្បន្ន ដែលកម្ពុជាត្រូវតែធ្វើទំនើបកម្ម និងបង្កើនភាពប្រកួតប្រជែងផលិតកម្មសាច់ ក្នុងលក្ខខណ្ឌសាមាហរណកម្មសេដ្ឋកិច្ចជាតិក្នុងតំបន់ និងសកលលោក។ |

| ដំណើរការ | ឈ្មោះ | មុខងារ | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|---|---|
| រៀបចំដោយ (ក្រសួងកសិកម្ម) | ១. លោក អ៊ុំ សាវី | ប្រធានផ្នែក RIA | | |
| | ២. លោក ហាវ ផា | អនុប្រធានផ្នែក RIA | | |
| | ៣. លោក ខេង យ៉ាសិទ្ធ | សមាជិកផ្នែក RIA | | |
| | ៤. លោក អ៊ិត កុំ | សមាជិកផ្នែក RIA | | |
| ត្រួតពិនិត្យដោយ (ORIA) | លោក ឈិត រតនៈ | សមាជិក RIA | | |
| | ឯ.ឧ. អេង រត្នមុនី | ប្រធានផ្នែក RIA | | |

| | | | | |
|---|---|---|---|---|
| | ឯ.ឧ. ម៉ម សារិទ្ធ | ប្រធានផ្នែក CBA | | |
| ឯកភាពដោយ (ORIA) | ឯ.ឧ ប៉ិច សុខា | ប្រធានគម្រោង | | |
| បញ្ចូលទិន្នន័យដោយ | | | | |
| | | | | |
| ប្រមូលឯកសារ និងចុះស្រង់ព័ត៌មាន | ១. លោក អ៊ុំ សារី<br>២. លោក ហាវ ផា<br>៣. លោក ខេង យ៉ាសិទ្ធ<br>៤. លោក អ៊ិត ភុំ | ប្រធានផ្នែក RIA<br>អនុប្រធានផ្នែក RIA<br>សមាជិកផ្នែក RIA<br>សមាជិកផ្នែក RIA | | |